ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

<u>នាយកដ្ឋានព័ត៌មាន</u>

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃដំណើរទស្សនកិច្ចផ្លូវការ របស់ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋតួកគី
# ថ្ងៃទី០១-០៣ ខែតុលា ឆ្នាំ២០១៨

* * * * * * *

ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋតួកគី នៅថ្ងៃទី០១-០៣ ខែតុលា ឆ្នាំ២០១៨ តបតាមការអញ្ជើញរបស់រដ្ឋមន្ត្រីការបរទេសតួកគី ឯកឧត្តម ម៉េវលុត ឆាវូស៊ូលុ។ ដំណើរទស្សនកិច្ចរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មានទិសដៅសំខាន់ក្នុងការរឹតចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការកម្ពុជា-តួកគីឲ្យកាន់តែជិតស្និទ្ធ និងរឹងមាំថែមទៀត និងត្រៀមរៀបចំដំណើរទស្សកិច្ចផ្លូវការរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋតួកគី នាពេលខាងមុខ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានជួបប្រជុំទ្វេភាគីប្រកបដោយផ្លែផ្កាជាមួយសមភាគីតួកគី ដែលក្នុងឱកាសនោះ ឯកឧត្តមរដ្ឋមន្ត្រីការបរទេសតួកគីបានកោតសរសើរការបោះឆ្នោតកាលពីខែកក្កដាកន្លងទៅនៅកម្ពុជា ដែលមានប្រជាជនចូលរួមដោយសេរី និងមានអត្រាខ្ពស់ ព្រមទាំងការគាំទ្រដ៏ច្រើនលើសលប់ដែលគណបក្សកាន់អំណាចទទួលបាន។ ឯកឧត្តម ម៉េវលុត ឆាវូស៊ូលុ បានសំដែងពីការត្រៀមខ្លួនរបស់តួកគីក្នុងការទទួលស្វាគមន៍ដំណើរទស្សនកិច្ចផ្លូវការរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** នៅទីក្រុងអង់ការ៉ា នាពេលខាងមុខ។

ដើម្បីរឹតចំណងមិត្តភាពឱ្យកាន់តែស្អិតរមួត និងពង្រឹងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ ភាគីកម្ពុជានឹងបើកស្ថានឯកអគ្គរាជទូតកម្ពុជានៅទីក្រុងអង់ការ៉ានៅឆ្នាំ២០១៩។ ភាគីតួកគីឯកភាពនឹងរៀបចំកិច្ចប្រជុំគណៈកម្មការសេដ្ឋកិច្ចចម្រុះលើកទី២ ឆាប់ៗខាងមុខ ដើម្បីដាក់ចេញនូវវិធានការបន្ថែមទៀតក្នុងការជំរុញភាពជាដៃគូពាណិជ្ជកម្ម និងសេដ្ឋកិច្ច រួមទាំងកិច្ចខិតខំប្រឹងប្រែងសំដៅសម្រេចអោយបាននូវគោលដៅនៃទំហំពាណិជ្ជកម្ម៥០០លានដុល្លារ នាឆ្នាំខាងមុខ។ រដ្ឋមន្ត្រីការបរទេសទាំងពីរបានឯកភាពផ្ទេ

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ការរួមគ្នា ដើម្បីពង្រីកកិច្ចសហប្រតិបត្តិការក្នុងវិស័យវិនិយោគ ពាណិជ្ជកម្ម ការហោះហើរត្រង់ បច្ចេកវិទ្យា ទេសចរណ៍ កសិកម្ម អប់រំ កីឡា វប្បធម៌ ធនធានទឹក ។ល។ ឯកឧត្តម ម៉េវលុត ឆាវូស៊ូលុ បានប្រកាសគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការបោសសំអាតមីន និងគាំទ្រដល់មជ្ឈមណ្ឌលសកម្មភាពមីនតំបន់អាស៊ាន ដែលមានទីតាំងនៅទីក្រុងភ្នំពេញ។ រដ្ឋមន្ត្រីការបរទេសទាំងពីរបានចុះហត្ថលេខាលើអនុស្សរណៈ ដើម្បីជំរុញកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានការទូតនៃក្រសួងការបរទេសនៃប្រទេសទាំងពីរ។

ភាគីទាំងពីរក៏បានធ្វើការផ្លាស់ប្តូរមតិយោបល់លើបញ្ហាអន្តរជាតិសំខាន់ៗមួយចំនួន និងបានផ្តល់សារៈសំខាន់ចំពោះភាពជាដៃគូសន្ទនាតាមវិស័យរវាងអាស៊ាន និងតួកគី ព្រមទាំងឯកភាពធ្វើការជាមួយបណ្តាប្រទេសជាសមាជិកអាស៊ានដ៏ទៃទៀត ដើម្បីសម្រេចឱ្យបាននូវវិស័យសម្រាប់កិច្ចសហប្រតិបត្តិការជាក់ស្តែងសម្រាប់ទំនាក់ទំនងអាស៊ាននិងតួកគី។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ចូលជួបពិភាក្សាការងារជាមួយ ឯកឧត្តម វ៉ុលកាន់ បូស្កៀរ ប្រធានគណៈកម្មាធិការកិច្ចការបរទេសនៃរដ្ឋសភាជាតិតួកគី។ កិច្ចសន្ទនាបានផ្តោតសំខាន់ជុំវិញវិធានការជាក់លាក់ដើម្បីជំរុញភាពជាដៃគូរវាងរដ្ឋសភានៃប្រទេសទាំងពីរ ក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី។ ភាគីទាំងពីរបានគូសបញ្ជាក់ពីតួនាទីនៃរដ្ឋសភាទាំងពីរ ដែលជាច្រកបន្ថែមជួយពង្រឹងកិច្ចសហប្រតិបត្តិការពាណិជ្ជកម្មនិងសេដ្ឋកិច្ច។ គណៈកម្មាធិការខាងលើ បានវាយតំលៃខ្ពស់ចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាដែលយកចិត្តទុកដាក់ចំពោះសហគមន៍មូស្លីម និងបង្កលក្ខណៈឱ្យពួកគាត់រស់នៅជាមួយប្រជាជនដ៏ទៃទៀតទាំងអស់ប្រកបដោយសុខដុមរមនា។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានចូលជួបសំដែងការគួរសមជាមួយ ឯកឧត្តម ប៊ីណាលី យីលឌីរីម ប្រធានរដ្ឋសភានៃសាធារណរដ្ឋតួកគី។ ភាគីទាំងពីរបានឯកភាពថា គំនិតផ្តួចផ្តើមច្បាស់លាស់ត្រូវការជាចាំបាច់ដើម្បីជួយឱ្យសម្រេចបាននូវគោលដៅពាណិជ្ជកម្មខាងលើ។ ភាគីតួកគីបានត្រៀមលក្ខណៈទទួលស្វាគមន៍គណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភាកម្ពុជា អញ្ជើញចូលរួមកិច្ចប្រជុំលើកទី៣នៃប្រធានសភារបស់ក្រុមប្រទេសនៅអាស៊ីអឺរ៉ុប ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៨-១១ ខែតុលា ឆ្នាំ២០១៨ នៅទីក្រុងអង់ការ៉ា។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានចូលជួបសំដែងការគួរសមជាមួយ ឯកឧត្តម ហ្វូអាត អុកតៃ អនុប្រធានាធិបតីនៃសាធារណរដ្ឋតួកគី ដែលក្នុងឱកាសនោះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានពាំនាំសារថ្លែងអំណរគុណរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ជូនចំពោះឯកឧត្តម រ៉ស៊ិប តាយីប អឺដូហ្គែន ប្រធានាធិបតីនៃសាធារណរដ្ឋតួកគី ដែលបានអបអរសាទរការបោះឆ្នោតនៅកម្ពុជានាពេលកន្លងមកជាមួយនឹងមេដឹកនាំពិភពលោកផ្សេងទៀត។ ភាគីទាំងពីរបានបញ្ជាក់សារជាថ្មីនូវការប្តេជ្ញាចិត្តជំរុញបន្ថែមនូវកិច្ចសហប្រតិបត្តិការនយោបាយនិងសេដ្ឋកិច្ច ព្រមទាំងការផ្លាស់ប្តូររវាងប្រជាជននិងប្រជាជននៃប្រទេសទាំងពីរ ដើម្បីធ្វើឱ្យទំនាក់ទំនងទ្វេភាគីកើនឡើងមួយកំរិតទៀត និងបានឯកភាពធ្វើការជាមួយគ្នាក្នុងការប្រយុទ្ធប្រឆាំងចំពោះការគំរាមគំហែងដល់អធិបតេយ្យភាព ឯករាជ្យភាព និងលទ្ធិប្រជាធិបតេយ្យនៃប្រទេសទាំងពីរ។៕

ថ្ងៃព្រហស្បតិ៍ ១០រោច ខែភទ្របទ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

ភ្នំពេញ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨